# មេរៀនទី ១៣៣: ព្រះបានអត់ទោសឲ្យដាវីឌ

## ២ សាំយូអែល ១២:១-៧, ទំនុកតម្កើង ៥១:១-១២

| | |
|---|---|
| **គោលបំណង៖** | ព្រះទទួលយកការប្រែចិត្តរបស់យើង។ |

**ខគម្ពីរចងចាំ៖ ទំនុកតម្កើង ៥១:១០** *"ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

អំពើបាបបានខណ្ឌចែករវាងព្រះនិងយើង ប៉ុន្តែព្រះយេស៊ូវបានចូលរួមជាមួយយើងម្តងទៀត តាមរយៈការសុគត និងការរស់ឡើងវិញរបស់ទ្រង់។ តាមរយៈព្រះយេស៊ូវយើងមានជីវិត និងឱកាសថ្មីដើម្បីប្រែចិត្តហើយចាប់ផ្តើមម្តងទៀត! សូមអាន **ទំនុកតម្កើង ៥១**។ យើងស្ទើតែអាចដឹងពីអារម្មណ៍របស់ដាវីឌទាំងស្រុងតាមរយៈទំនុកចម្រៀងរបស់គាត់។ តើលើកចុងក្រោយពេលណា ដែលអ្នកមានវិប្បដិសារីចំពោះអំពើបាបរបស់អ្នក ហើយអស់សង្ឃឹមក្នុងការកម្ចាត់វាចោល? អរគុណព្រះយេស៊ូវសម្រាប់ភាពបរិសុទ្ធ ដែលទ្រង់បានញែកយើងចេញពីអំពើបាប។ បើគ្មានការលះបង់របស់ព្រះយេស៊ូវទេ នោះយើងនឹងធ្លាក់ទៅក្នុងអំពើបាបជារៀងរហូត។

**ចំរៀង៖** ១. ចូរប្រយ័ត្ននឹងភ្នែកតូចអ្នក ២. នៅរស់ ៣. ខ្ញុំដឹងខ្លួនហើយ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «លើ ក្រោម ដំ»



១. ឲ្យកុមារឈរ២នាក់ទល់មុខគ្នាដោយក្តាប់ដៃ ដាក់ឆ្លាស់គ្នាលើក្រោម។

២. គ្រូជាអ្នកស្រែក"លើ ក្រោម ដំ"កុមារដែលមានដៃនៅខាងលើគេត្រូវព្យាយាមដំដៃ ដៃគូររបស់គេ បើកុមារដំចំដៃរបស់ដៃគូរ កុមារនោះជាអ្នកឈ្នះ កុមារដែលមានដៃនៅខាងក្រោមត្រូវដកដៃអោយលឿននៅពេលលឺពាក្យ ថា"ដំ"។

៣. ល្បែងនេះបានបង្ហាញថា ការប្រុងប្រយ័ត្ននឹងមិននាំឲ្យយើងអន្តរាយដូចជាសាច់រឿងនៅថ្ងៃនេះនោះទេ។

### ៤. ការណែនាំមេរៀន

តើមានប្អូនៗប៉ុន្មាននាក់ធ្លាប់ជេគេខ្លះ? ចុះតើមានប្អូនៗណាខ្លះត្រូវបានគេជេ? តើការជេជាការល្អឬអាក្រក់? បាទ/ចាសការជេអត់ល្អទេ។ ប្រសិនបើមានគេជេប្អូន តើប្អូនសើចឬក៏ខឹង? តើការជេជាអំពើបាបដែរឬទេ? បាទ/ចាស វាគឺជាអំពើបាប។ តើអំពើបាបមានអ្វីខ្លះ? នៅពេលដែលប្អូនលួចគេ ជេរគេ វ៉ៃគេ កុហក គេ ស្អប់គេ សំលាប់គេ អញ្ចឹងអំពើបាបជាការគិតខុស និយាយខុស និងធ្វើខុស ដែលព្រះមិនសព្វព្រះ ហឫទ័យ។ យើងត្រូវសារភាពអំពើបាបរបស់យើងចំពោះព្រះហើយប្រែចិត្ត។ ការប្រែចិត្តមានន័យថា សុំការអភ័យទោសពីព្រះ ហើយងាកចេញ

ពីអំពើបាប។ ថ្ងៃនេះ យើងនឹងរៀនអំពីស្តេចដាវីឌ ដែលបានធ្វើបាបទាស់នឹងព្រះ និងការប្រែចិត្តរបស់គាត់។ តើអ្នកគិតថាព្រះនឹងអត់ទោសឱ្យ គាត់ដែរឬទេ?

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយហោរាណាថាន់បានទៅសួរសុខទុក្ខស្តេចដាវីឌ។ សូមចាំថាហោរា គឺជាអ្នកនាំសាររបស់ព្រះ។ ព្រះបានផ្តល់ព្រះបន្ទូលដល់ហោរាដើម្បីឲ្យអ្នកដទៃទៀតបានឮដែរ។ ណាថាន់បានចាប់ផ្តើមចែកចាយសារ របស់ព្រះដោយការនិទានរឿងមួយ។

គាត់បានប្រាប់អំពីបុរសអ្នកមានម្នាក់ដែលគាត់មានអ្វីៗគ្រប់យ៉ាង រួមទាំងចៀមនិងគោជាច្រើនផងដែរ។ គាត់ក៏បាននិយាយអំពីបុរសក្រីក្រម្នាក់ ដែលគាត់មានតែចៀមតូចមួយប៉ុណ្ណោះ។ បុរសក្រីក្រនោះស្រលាញ់កូនចៀមនោះខ្លាំងណាស់ ហើយចាត់ទុកវាដូចជាសត្វចិញ្ចឹម។ ថ្ងៃមួយអ្នកដំណើរម្នាក់បានទៅលេងផ្ទះរបស់បុរសអ្នកមាននោះ។ ជាធម្មតាអ្នកមានត្រូវរៀបចំអាហារសម្រាប់ភ្ញៀវរបស់គាត់ ប៉ុន្តែជំនួសឱ្យការប្រើសត្វ ដែលគាត់ចិញ្ចឹម គាត់បានលួចចៀមតែមួយរបស់បុរសក្រីក្រនោះ។

ដាវីឌបានគិតថាវាជាការអយុត្តិធម៌ដែលបុរសអ្នកមានយកចៀមរបស់អ្នកក្រ។ ពេលនោះដាវីឌគាត់ខឹងណាស់! នេះជាពេលដែលណាថាន់ប្រាប់ដាវីឌនូវសារពិតពីព្រះអំពីកំហុសរបស់ដាវីឌ។ ណាថាន់បាននិយាយថា៖ «ដាវីឌ នេះជាអ្វីដែលអ្នកបានធ្វើ»។ ដាវីឌចាប់ផ្តើមគិតអំពីអំពើបាបរបស់គាត់។

ដាវីឌនឹកចាំថា នៅរដូវផ្ការីកពេលស្តេចទាំងអស់ចេញទៅច្បាំង តែដាវីឌសម្រេចចិត្តនៅរាជវាំង។ ដាវីឌបានចាត់មេទ័ពរបស់លោកគឺលោកយ៉ូអាប់ទៅធ្វើសង្គ្រាមជំនួសវិញ។ នៅល្ងាចថ្ងៃមួយ ពេលដែលដាវីឌដើរជុំវិញរាជវាំង គាត់បានឃើញស្ត្រីស្អាតម្នាក់នៅក្បែរនោះ។ ដាវីឌក៏ចាត់អ្នកនាំសារម្នាក់ឲ្យនាំស្ត្រីនោះទៅរាជវាំង។

ស្តេចដាវីឌបានប្រព្រឹត្តចំពោះស្ត្រីដ៏ស្រស់ស្អាតឈ្មោះបាតសេបា នោះដូចជាភរិយារបស់គាត់ដែរ។ គាត់បានរកឃើញថានាងបានរៀបការជាមួយ អ៊ូរី ជាទាហានដែលប្រយុទ្ធក្រោមការបញ្ជារបស់យ៉ូអាប់។ ជំនួសឲ្យការប្រែចិត្តក្នុងការចង់បានប្រពន្ធអ៊ូរីស្តេចដាវីឌបានផ្ញើសារទៅយ៉ូអាប់ ដោយប្រាប់គាត់ឲ្យដាក់អ៊ូរីនៅសមរភូមិជួរមុខ ដើម្បីសម្លាប់អ៊ូរីចោល។ ពេលដំណឹងនេះបានដឹងដល់ដាវីឌថា អ៊ូរីត្រូវគេសម្លាប់ក្នុងសមរភូមិហើយនោះ គាត់ក៏បានរៀបការជាមួយនាងបាតសេបា។

នៅចាំរឿងនិទានរបស់ណាថាន់ដែរឬទេ? ដាវីឌបានដឹងថាគាត់ក៏ដូចជាបុរសអ្នកមានបានលួចចៀមនោះអីចឹង គាត់ក៏បានលួចប្រពន្ធរបស់អ្នកដទៃដែរ។ គាត់ស្ទើរតែស្លាប់ដោយសារតែគាត់មានការសោកស្តាយចំពោះអ្វីដែលគាត់បានធ្វើ។ គាត់បានសុំការអភ័យទោសពីព្រះ ហើយបានសរសេរ **ទំនុកតម្កើង ៥១** ដើម្បីបង្ហាញពីការប្រែចិត្តរបស់គាត់។ យើងទាំងអស់គ្នាបានធ្វើបាប។ ព្រះគម្ពីរប្រាប់ថាយើងទាំងអស់គ្នាខ្វះភាពល្អឥតខ្ចោះ។ យើងទាំងអស់គ្នាមានអំពើបាបដែលយើងត្រូវប្រែចិត្ត។ យើងអាចទូលប្រាប់ព្រះអំពីអំពើបាបរបស់យើង។ នោះគេហៅថាការសារភាពបាប។ ហើយយើងអាចសន្យាជាមួយព្រះថាយើងចង់ធ្វើឲ្យត្រឹមត្រូវ ហើយថាយើងនឹងខំឲ្យអស់ពីសមត្ថភាពដើម្បីមិនប្រព្រឹត្តអំពើបាបនោះម្តងទៀត។ នោះហៅថាការប្រែចិត្ត។ ពេលយើងសារភាពហើយប្រែចិត្ត យើងអាចប្រាកដថា ព្រះទទួលយកការសុំទោសរបស់យើង។ យើងដឹងថាព្រះបានអត់ទោសឲ្យយើង ដោយសារ

ទ្រង់បានបញ្ជូនព្រះយេស៊ូវឲ្យសុគតជំនួសរាល់អំពើបាបរបស់យើង!

## ៧. ល្បែងកំសាន្ត « ខ្លែងឆាបកូនមាន់»



១. បែងចែកកុមារជា ២ក្រុម ឬច្រើនជាងនេះ

២. ក្នុងក្រុមនីមួយៗកុមារត្រូវតោងចង្កេះគ្នា។ អ្នកដែលនៅឈរមុខគេគឺត្រូវតាមចាប់យកអ្នក ក្រោយគេនៃក្រុមផ្សេងទៀត ហើយក៏ត្រូវព្យាយាមការពារកូនក្រុមខ្លួនឯងផងដែរ (កន្ទុយក្រោយគេ)

៣. តាមរយៈល្បែងនេះបានបង្ហាញថា ទោះស្ថិតក្នុងកាលៈទេសៈបែបណាមេមាន់ព្យាយាមកាពារកូនរបស់គេ។ ហើយដូចជាព្រះអញ្ចឹងដែរ ព្រះតែងតែកាពារនិងអត់ទោសដល់យើងនៅពេលយើងប្រែចិត្តពីអំពើបាប។

## ៦. សំនួរពិភាក្សា

១. តើនៅក្នុងរឿងនិទានរបស់ហោរាណាថាន់អ្នកមានបានធ្វើអ្វី? *គាត់បានលួចចៀមតែ១ពីបុរសក្រីក្រម្នាក់ដើម្បីរៀបចំអាហារពេលល្ងាចសម្រាប់ភ្ញៀវរបស់គាត់ ជំនួសឲ្យការប្រើសត្វរបស់គាត់។*

២. តើស្តេចដាវីឌ និងបុរសអ្នកមាននោះមានភាពស្រដៀងគ្នាត្រង់ណា?
*លួចប្រពន្ធអ្នកផ្សេង ហើយសម្លាប់ប្តីរបស់នាងនៅក្នុងសង្គ្រាម*

៣. តើស្តេចដាវីឌបានធ្វើអ្វី ពេលគាត់បានដឹងពីអំពើបាបដែលគាត់បានប្រព្រឹត្ត?
*គាត់បានសារភាពកំហុស ហើយប្រែចិត្តចំពោះព្រះ*

៤. តើការប្រែចិត្តមានន័យដូចម្តេច ?
*សន្យាថាយើងនឹងប្រឹងឲ្យអស់ពីសមត្ថភាពថា មិនប្រព្រឹត្តអំពើបាបដដែលនោះម្តងទៀតទេ*

៥. តើយើងអាចប្រាកដថាព្រះអត់ទោសឲ្យយើងដោយរបៀបណា ពេលយើងប្រែចិត្ត?
*ទ្រង់បានចាត់ព្រះយេស៊ូវឲ្យមកសុគតសម្រាប់អំពើបាបរបស់យើង*

## ៨. ខគម្ពីរចងចាំ ទំនុកតម្កើង ៥១:១០

## ៩. ហត្ថកម្ម «សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ»

**សម្ភារៈដែលត្រូវការ៖** រូបបេះដូង កូល័រ និងប៊ិក

១. សូមបោះពុម្ពរូបភាពបេះដូងសម្រាប់កុមារគ្រប់ៗគ្នា



២. សរសេរខគម្ពីរចងចាំ «**ទំនុកតម្កើង ៥១:១០** "ឱព្រះអង្គអើយ សូមបង្កើតចិត្តបរិសុទ្ធនៅក្នុងទូលបង្គំ ហើយកែវិញ្ញាណក្នុងទូលបង្គំឲ្យត្រឹមត្រូវឡើង។"» នៅចំកណ្តាលបេះដូងនោះ។ ប្រសិនបើកុមារមួយចំនួន មានការពិបាកក្នុងការសរសេរអក្សរ សូមឲ្យពួកគេ សរសេរតែ "សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ"។

៣. ឲ្យសិស្សផាត់ពណ៌បេះដូង និងដៃ។

៤. សូមរំឭកកុមារថា ព្រះតែងតែអត់ទោសឲ្យយើង ពេលយើងចេះប្រែចិត្តដូចស្តេចដាវីឌ!

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

## សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ



## សូមបង្កើតដួងចិត្តបរិសុទ្ធក្នុងទូលបង្គំ

